# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៥...ស.ជ.ន

## សារលិខិត

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**

**ជនរួមជាតិកម្ពុជាក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ**

**ឆ្នាំវក អដ្ឋស័ក ព.ស. ២៥៦០**

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីសម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ

សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា ជាទីស្នេហា

ថ្ងៃ៧កើត ថ្ងៃ៨កើត ថ្ងៃ៩កើត និងថ្ងៃ១០កើត ខែចេត្រ ព.ស.២៥៦០ ត្រូវនឹងថ្ងៃពុធទី១៣ ថ្ងៃព្រហស្បតិ៍ទី១៤ ថ្ងៃសុក្រទី១៥ និងថ្ងៃសៅរ៍ទី១៦ ខែមេសា ឆ្នាំ២០១៦ គឺជាទិវាដ៏នក្ខត្តឫក្ស ដែលប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា ប្រារព្ធពិធីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក អដ្ឋស័ក ព.ស. ២៥៦០ ប្រកបដោយក្តីសោមនស្សរីករាយ សិរីសួស្តី និងជ័យមង្គលដ៏ឧត្តុង្គឧត្តមក្នុងគ្រួសារ និងសង្គមជាតិទាំងមូល។

នៅក្នុងឱកាសដ៏វិសេសវិសាល នៃការប្រារព្ធពិធីបុណ្យប្រពៃណីជាតិរបស់ប្រជាជាតិខ្មែរយើងនេះ ទូលបង្គំខ្ញុំ ព្រះករុណាខ្ញុំ សូមចូលរួមអំណរសាទរជាមួយបងប្អូនជនរួមជាតិទាំងអស់ដែលកំពុងរស់នៅក្នុង និងក្រៅប្រទេស ប្រកបដោយទឹកចិត្តជ្រះថ្លា និងសេចក្តីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នឹងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនទៀត ក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ និងកសាងមាតុភូមិកម្ពុជា។

ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក អដ្ឋស័ក ព.ស.២៥៦០ នេះប្រព្រឹត្តទៅស្របពេលដែលរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា បានឈានដំណើរដល់ជាងពាក់កណ្តាលអាណត្តិរបស់ខ្លួន និងកំពុងបោះជំហានទៅមុខលើមាគ៌ានៃការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងជាឆ្នាំត្រៀមរៀបចំខ្លួន ដើម្បីអនុវត្តសហគមន៍សេដ្ឋកិច្ចអាស៊ានចាប់តាំងពីដើមឆ្នាំ២០១៦ តទៅ។

ក្នុងឆ្នាំកន្លងផុតទៅនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែង តស៊ូ ពុះពារ និងអត់ធ្មត់ ហើយជំនះបាននូវការលំបាក និងបញ្ហាប្រឈមគ្រប់បែបយ៉ាង ទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីអភិវឌ្ឍប្រព័ន្ធនយោបាយមួយ ដែលធ្វើឲ្យព្រះរាជាណាចក្រកម្ពុជា អាចរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង

សណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរ ធានាបានកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ ក្នុងលក្ខខណ្ឌអតិផរណាទាប រក្សាបាននូវភាពទាក់ទាញវិនិយោគ បង្កើតការងារជូនប្រជាពលរដ្ឋ និងដោះស្រាយបាននូវបញ្ហាប្រឈមគ្រប់វិស័យក្នុងកម្រិតមួយគួរឲ្យកត់សម្គាល់។

ក្នុងឆ្នាំ២០១៥ ដែលត្រូវនឹងឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ កន្លងទៅ តាមការប៉ាន់ស្មាន កំណើនសេដ្ឋកិច្ចកម្ពុជា អាចសម្រេចបានក្នុងរង្វង់ ៧% ក្នុងនោះ វិស័យឧស្សាហកម្មមានកំណើន ៨,៧% វិស័យសេវាកម្មមានកំណើន ៩% និងវិស័យកសិកម្មមានកំណើន១%។ នៅក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ កម្ពុជាបានធ្វើដំណើរទៅមុខ ហើយនៅឆ្នាំ២០១៦ ដែលត្រូវនឹងឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ នេះកម្ពុជានឹងចាកចេញពីចំណាត់ថ្នាក់ប្រទេសមានប្រាក់ចំណូលកម្រិតទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ប្រាក់ចំណូលប្រចាំឆ្នាំ គិតជាមធ្យមក្នុងប្រជាពលរដ្ឋម្នាក់ មាន ១ ១៣៦ ដុល្លាអាមេរិក នៅឆ្នាំ ២០១៤ ហើយបានកើនឡើងដល់ ១ ២៣៨ ដុល្លាអាមេរិក នៅឆ្នាំ២០១៥ ធ្វើឲ្យកម្រិតនៃភាពក្រីក្រធ្លាក់ចុះពី ៤៧,៨% នៅឆ្នាំ២០០៧ មក ១៤% នៅឆ្នាំ២០១៤ និងបន្តធ្លាក់ចុះទៀតនៅឆ្នាំបន្តបន្ទាប់។ ទន្ទឹមនេះ កម្ពុជាក៏ចាំបាច់ត្រូវរៀបចំខ្លួនឲ្យបានល្អ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង សំដៅទាញយកអត្ថប្រយោជន៍ពីសហគមន៍សេដ្ឋកិច្ចអាស៊ានផងដែរ។

រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា បានបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីលើកកម្ពស់វិស័យអប់រំនៅកម្ពុជា តាមរយៈការពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិតសិក្សា ពិសេសនៅមធ្យមសិក្សា ការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់យុវជន និងការបណ្តុះបណ្តាលភាសាបរទេស ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍប្រទេសក្នុងបរិបទថ្មី ដែលកម្ពុជាបានធ្វើសមាហរណកម្មចូលសហគមន៍សេដ្ឋកិច្ចអាស៊ានចាប់ពីចុងឆ្នាំ២០១៥មក។ ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ប្រកបដោយជោគជ័យក្នុងវិស័យអប់រំ តាមរយៈការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយទទួលបាននូវការពេញចិត្តពីសំណាក់អាណាព្យាបាលនៃសិស្សានុសិស្ស និងសិស្សានុសិស្សដែលខិតខំសិក្សា ក្រោមពាក្យស្លោកថា "អ្នកចេះប្រឡងជាប់"។

មានផ្លូវ គឺមានសេចក្តីសង្ឃឹម នៅក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពល្អប្រសើរ ក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ផ្លូវគោកក្នុងប្រទេស និងការតភ្ជាប់ទៅនឹងតំបន់។ ជាក់ស្តែងក្នុងឆ្នាំមមែ សប្តស័ក ព.ស.២៥៥៩ រាជរដ្ឋាភិបាលបានដាក់ឲ្យដំណើរការនូវផ្លូវ ស្ពានអាកាស និងស្ពានឆ្លងកាត់ទន្លេ មានជាអាទិ៍ ផ្លូវជាតិលេខ៤១ បំបែកពីផ្លូវជាតិលេខ៤ ត្រង់ថ្នល់ទទឹង ខេត្តកំពង់ស្ពឺ ទៅដល់ផ្លូវជាតិលេខ៣ នៅជងទង់ ខេត្តកំពត ស្ពានមិត្តភាពកម្ពុជា ចិន (ស្ពានតាខ្មៅ ឆ្លងកាត់ទន្លេបាសាក់) ខេត្តកណ្តាល ស្ពានមិត្តភាពកម្ពុជា ចិន (ស្ពានជ្រោយចង្វារទី២ឆ្លងកាត់ទន្លេសាប) រាជធានីភ្នំពេញ ស្ពានអាកាស៥មករា (ស្ពានអាកាសតិចណូ ស្តុបទួលគោក) រាជធានីភ្នំពេញ ។ល។ ទន្ទឹមនេះ ការដ្ឋានសំណង់ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវចាប់ផ្តើមឲ្យមានការសិក្សា និងបានបើកការដ្ឋានសាងសង់ ជាបន្តបន្ទាប់ផងដែរ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍប្រទេសជាតិ។

ស្របតាមគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាលនៅតែបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ ការបញ្ចុះថ្លៃអគ្គិសនីឲ្យបានសមរម្យ និងការពង្រឹងយន្តការស្ថាប័ន និងសមត្ថភាពគ្រប់គ្រង។ ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាល បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវវារីអគ្គិសនី ស្ទឹងឫស្សីជ្រុំក្រោម មានអានុភាព ៣៣៨មេហ្គាវ៉ាត់ និងវារីអគ្គិសនីស្ទឹងតាតៃ មានអានុភាព ២៤៦ មេហ្គាវ៉ាត់ នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា និងនៅឃុំតាតៃ ស្រុកកោះកុង

ខេត្តកោះកុង បន្ថែមពីលើវារីអគ្គិសនី និងរោងចក្រអគ្គិសនីមួយចំនួនទៀត ដែលបានដាក់ឲ្យដំណើរការរួចហើយ និងកំពុងដំណើរការសាងសង់។ រហូតមកដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលបានចាត់ចែងឲ្យមានការតភ្ជាប់ចរន្តអគ្គិសនីចូលដល់បន្ទប់ស្នាក់នៅរបស់កម្មករ និងប្រជាពលរដ្ឋ ដែលស្នាក់អាស្រ័យនៅតាមបន្ទប់ និងផ្ទះជួលនៅរាជធានីភ្នំពេញបានប្រមាណ ២១០ពាន់បន្ទប់ រួចហើយ ដើម្បីរួមចំណែកសម្រួលជីវភាពរស់នៅរបស់បងប្អូន ព្រមទាំងបាននិងកំពុងជំរុញការអនុវត្តអគ្គិសនីភាវូបនីយកម្មជនបទ។

ការអភិវឌ្ឍឧស្សាហកម្ម ក៏ជាយុទ្ធសាស្ត្រមួយ ដែលបានកំណត់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ដើម្បីប្រែក្លាយសក្តានុពលវិស័យនេះ ឲ្យក្លាយទៅជាប្រភពមួយទៀត នៃកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ គិតមកដល់ដំណាច់ឆ្នាំ២០១៥នេះ រោងចក្រឧស្សាហកម្មធំៗមានប្រមាណជាង១ ៤០០ ដែលមានពលករបម្រើការងារប្រមាណ ៨៦០ពាន់នាក់ និងមូលដ្ឋានឧស្សាហកម្មតូច និងសិប្បកម្មមានប្រមាណ ៣៩ ពាន់មូលដ្ឋាន ដែលមានពលករបម្រើការងារប្រមាណ ១៩៤ ពាន់នាក់។

រាជរដ្ឋាភិបាលបានបន្តដោះស្រាយបញ្ហាប្រឈមមួយចំនួន ដើម្បីបង្កើនសមត្ថភាពស្រោចស្រពសំដៅបង្កើនផលដំណាំផ្ទុះ លើកកម្ពស់ផលិតភាពកសិកម្ម និងបង្កើនបរិមាណផលិតផល សម្រាប់បម្រើសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ។ ចំពោះការបង្កើនសមត្ថភាពនិងវិសាលភាពការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ និងទីប្រជុំជន តាមរយៈការជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ២០១១-២០២៥វិញ ក្នុងឆ្នាំកន្លងទៅ អង្គភាពរដ្ឋាករទឹកសាធារណៈនិងរដ្ឋាករទឹកឯកជនទូទាំងប្រទេសបាននិងកំពុងផលិតទឹកស្អាតសម្រាប់ផ្គត់ផ្គង់ជូនប្រជាពលរដ្ឋ នៅតាមរាជធានី ខេត្ត និងទីប្រជុំជននានា។

បរិមាណផលិតផលស្រូវរដូវវស្សានិងស្រូវរដូវប្រាំងក្នុងឆ្នាំកន្លងទៅ សម្រេចបានប្រមាណជាង ៩លានតោន និងសល់ស្រូវជាង៤លាន ៥សែនតោន គិតជាអង្ករប្រមាណ ២លាន ៩សែនតោន សម្រាប់បម្រើគោលដៅនាំចេញ ហើយដែលឆ្នាំកន្លងទៅការនាំចេញអង្ករមានប្រមាណជាង ៥សែនតោន។ ភ្ញៀវទេសចរអន្តរជាតិបានចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០១៥ មានចំនួនប្រមាណ ៤លាន ៧សែននាក់ បង្កើតការងារឲ្យវិស័យឧស្សាហកម្មទេសចរណ៍ដោយផ្ទាល់មានប្រមាណ ៦២ ម៉ឺននាក់។ ក្នុងរយៈពេលនេះដែរ រាជរដ្ឋាភិបាល បានផ្តល់លិខិតអនុញ្ញាតសាងសង់ទូទាំងប្រទេសចំនួនប្រមាណ ២ ៣០០ គម្រោង ដែលមានផ្ទៃក្រឡាសំណង់សរុបប្រមាណជាង ៧លាន ៦សែនម៉ែត្រការ៉េ មានទឹកប្រាក់វិនិយោគសរុបប្រមាណ ៣ ប៊ីលានដុល្លារអាមេរិក។

ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលបានបន្តធ្វើកំណែទម្រង់ស៊ីជម្រៅ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះរួមមាន ការពង្រឹងការប្រមូលចំណូលគយនិងពន្ធដារ ការដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងនិវត្តជន ជាពិសេស គ្រូបង្រៀន និងគ្រូពេទ្យ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលក៏បានធ្វើកំណែទម្រង់ប្រព័ន្ធបៀវត្ស និងប្រព័ន្ធរដ្ឋបាលសាធារណៈ ហើយប្រការដែលសំខាន់បំផុតនោះ គឺការធានាបាននូវការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធធនាគារបានទាន់ពេលវេលា ក្នុងសប្តាហ៍ទី៤នៅដំណាច់ខែនីមួយៗ។ ជារួម ការធ្វើកំណែទម្រង់ត្រូវបានអនុវត្តប្រកបដោយការទទួលខុសត្រូវនៅគ្រប់ក្រសួង ស្ថាប័នរដ្ឋ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រកាន់យកនូវអភិក្រមការងារទាំងបួន គឺៈ -ឆ្លុះកញ្ចក់

ងួតទឹក ផុសក្អែល និងព្យាបាល" ដែលជាកត្តាចាំបាច់ឲ្យសម្រេចបាននូវសុខដុមនីយកម្មខាងនយោបាយ និងធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងឆ្នាំ២០១៥ សភាពការណ៍ពិភពលោកមានការវិវត្តស្មុគស្មាញយ៉ាងខ្លាំង ទាំងផ្នែកសេដ្ឋកិច្ច យោធា និងការទូត ការប្រែប្រួលអាកាសធាតុ បញ្ហាសន្តិសុខស្បៀង ថាមពល ឧក្រិដ្ឋកម្មឆ្លងដែន ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ការរីកសាយនៃអាវុធប្រល័យលោក។ល។ ប៉ុន្តែទោះជាយ៉ាងណាក្តី ប្រទេសទាំងអស់នៅលើពិភពលោកបានប្រកាន់យកនូវនិន្នាការរួមមួយ គឺការថែរក្សាសន្តិភាព ស្ថិរភាព ដែលជាលក្ខណៈសំខាន់បំផុតពុំអាចខ្វះបានសម្រាប់ការអភិវឌ្ឍ ដើម្បីផលប្រយោជន៍សម្រាប់មនុស្សជាតិទាំងមូល។ ស្ថិតចំពោះមុខនៃការវិវត្តនៃស្ថានការណ៍អន្តរជាតិបែបនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបន្តប្រកាន់ខ្ជាប់នូវនយោបាយអព្យាក្រឹតមិនចូលបក្សសម្ព័ន្ធ និងសន្តិសហវិជ្ជមាន ក្នុងបរិបទនៃការប្រកួតប្រជែងរវាងប្រទេសមហាអំណាច ព្រមទាំងជំរុញឲ្យមានការដោះស្រាយរាល់ជម្លោះទាំងអស់តាមរយៈដំណោះស្រាយនយោបាយ និងចរចាដោយសន្តិវិធីស្របតាមច្បាប់អន្តរជាតិ និងគោលការណ៍អធិបតេយ្យ។

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ**

**សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ ជាទីស្នេហា**

រាល់សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងទៅនេះ គឺអាស្រ័យដោយមានការដឹកនាំខាងនយោបាយត្រឹមត្រូវ មានការចូលរួមគាំទ្រពីសមាជិក សមាជិកានៃស្ថាប័ននីតិប្បញ្ញត្តិ សមាជិក សមាជិការាជរដ្ឋាភិបាល មន្ត្រីរាជការស៊ីវិលគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋទូទាំងប្រទេសប្រកបដោយឆន្ទៈមោះមុត ទោះបីមាននិន្នាការនយោបាយ ដើមកំណើតជាតិ ជំនឿសាសនា ឬតួនាទីក្នុងសង្គមផ្សេងៗគ្នាក៏ដោយ។ ព្រមជាមួយនេះដែរ ក៏មានការជួយឧបត្ថម្ភគាំទ្រដ៏ស្មោះសពីបណ្តាប្រទេសជាមិត្ត និងសហគមន៍អន្តរជាតិផងដែរ។

សម្រាប់ឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ព.ស.២៥៦០ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងខិតខំពុះពារគ្រប់បែបយ៉ាង ដើម្បីបន្តថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈឲ្យបានកាន់តែរឹងមាំ ការពាររដ្ឋធម្មនុញ្ញនិងការពាររាល់សមិទ្ធផលដែលរាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋទាំងមូលសម្រេចបាន ទប់ស្កាត់រាល់សកម្មភាពប្រខុសរ៉ាយដែលប៉ុនប៉ងនាំប្រទេសជាតិឲ្យធ្លាក់ទៅក្នុងភាពច្របូកច្របល់ វឹកវរ អស្ថិរភាពក្នុងសង្គម ព្រមទាំងបន្តជំរុញកំណែទម្រង់គ្រប់វិស័យ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដោយប្តេជ្ញាចិត្តខ្ពស់ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អរបស់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គុណភាព ហើសទាន់ពេលវេលា និងមានការជឿទុកចិត្តពីប្រជាពលរដ្ឋ។

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ**

**សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ ជាទីស្នេហា**

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ព.ស.២៥៦០ នេះ ក្នុងនាមរាជរដ្ឋាភិបាលនិងក្នុងនាមទូលបង្គំជាខ្ញុំ ព្រមទាំងមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ទូលបង្គំជាខ្ញុំ សូមលំឱនកាយវាចាចិត្ត គោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ព្រះនាម **មណ្ឌាទេវី** សូមប្រោះព្រំសព្ទសាធុការពរ បវរមហាប្រសើរ ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋខ្មែរ ជាកូន ជាចៅ ចៅទួត ជានិច្ចនិរន្តរ៍តរៀងទៅ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះដែរ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមទូលបង្គំខ្ញុំ ព្រះករុណាខ្ញុំ សូមថ្វាយនិងប្រគេនព្រះពរចំពោះសម្តេចអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះសង្ឃគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់ជាម្លប់របស់ពុទ្ធបរិស័ទក្នុងព្រះរាជាណាចក្រកម្ពុជា ជានិច្ចនិរន្តរ៍តរៀងទៅ និងសូមជូនពរដល់ជនរួមជាតិខ្មែរគ្រប់រូបដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស មន្ត្រីរាជការ នាយទាហាន ពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលបាននិងកំពុងបំពេញភារកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅតំបន់ព្រំដែន និងកំពុងបំពេញបេសកកម្មរក្សាសន្តិភាព និងមនុស្សធម៌នៅក្រៅប្រទេស នាយនគរបាល ពលនគរបាល ដែលបាននិងកំពុងរួមចំណែកការពារបូរណភាពទឹកដី និងថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ និយោជិត ធុរជន និងវិនិយោគិន ដែលកំពុងប្រកបធុរកិច្ចនៅលើទឹកដីកម្ពុជា សូមទទួលបាននូវភាពជោគជ័យ សិរីសួស្តី ជ័យមង្គល និងវិបុលសុខ ជាដរាបតរៀងទៅ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **មណ្ឌាទេវី** ជួយអភិបាលគ្រប់គ្រង តាមប្រោះព្រំសព្ទសាធុការពរ ជួយបីបាច់ ថែរក្សាគាំពារ និងប្រសិទ្ធពរជ័យដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឲ្យមានសមានចិត្តជាកុសល ប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ទាំងបួន គឺ មេត្តា ករុណា មុទិតា ឧបេក្ខា រួបរួមសាមគ្គីគ្នារឹងមាំ រួមសុខ រួមទុក្ខ ជាមហាគ្រួសារខ្មែរតែមួយ នៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ប្រកបដោយសុខក្សេមក្សាន្ត កិត្តិយស និងសេចក្តីថ្លៃថ្នូរ តរៀងទៅ។

*សូមអរព្រះគុណនិងអរគុណ!*

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**